**EMBASSY OF JAPAN**
**IN THE KINGDOM OF CAMBODIA**

# PRESS RELEASE

No. 03PR-25/EoJ　　　　　　　　　　　　　　　　30 January 2025

## Japan Provides US$446,801 for Irrigation Facility Rehabilitation and Construction of Bridges

The Government of Japan will provide US$446,801 in total for three recipient organizations under the framework, *the Grant Assistance for Grassroots Human Security Projects ("KUSANONE")*. The Grant Contracts were signed today between H.E. Mr. UENO Atsushi, Ambassador Extraordinary and Plenipotentiary of Japan to the Kingdom of Cambodia, and the representatives of three recipients respectively, to carry out the following projects.

1. 'The Project for the Rehabilitation of Trapeang Krek Irrigation Facilities in Takeo Province' (US$180,396)
Recipient: Takeo Provincial Department of Water Resources and Meteorology
This grant will be used to rehabilitate the existing irrigation facilities with declined reservoir functions. This area is drought-prone during the dry season because the facilities cannot store adequate amount of water during the rainy season. Moreover, due to the insufficient water storage capacity, this area is often affected by floods. The roads connecting the facilities to the resident area are in poor condition and consequently lay a heavy burden on farmers. It is expected to benefit over 3,000 local residents by improving the irrigation facilities so that agricultural water will be secured and supplied in a stable manner throughout the year. In addition, improvement of residents' standard of living and incomes is anticipated as a result of an increased amount of rice produced in this area.

2. 'The Project for the Construction of Bridge in Chhouk Commune, Prasat Sambour District, Kampong Thom Province' (US$154,353)
Recipient: Kampong Thom Provincial Department of Public Works and Transport
This grant will be used to construct a new concrete bridge. There was an incomplete bridge that the construction was halted due to lack of funds. After it collapsed by floods in 2023, local residents had to cross the river in a small boat. This new bridge will provide around 11,000 residents living this area with safe transportation. In addition, by enabling transportation of

agricultural products, an increase in local population's incomes is anticipated.

3. 'The Project for the Construction of Bridge in Khav Commune, Chi Kraeng District, Siem Reap Province' (US$112,052)

Recipient: Khav Commune Administration

This grant will be used to replace the existing fragile wooden bridge with a new concrete bridge. While many local residents regularly cross the bridge to go to school, work and hospital as well as to transport agricultural products, the bridge is damaged and became unsafe especially for children and the elderly. Furthermore, cars and emergency vehicles are not allowed to cross the bridge because it may not be able to bear the weight and can collapse. It is expected to benefit around 15,000 residents by securing a safe path to the nearest school, market and health center throughout the year. The construction of a new bridge will also facilitate transportation of agricultural products, and therefore the improvement of standard of living of the residents and the increase of farmers' income are anticipated.

Japan's *"KUSANONE" Projects* started in Cambodia in 1991 in order to support Cambodia's reconstruction and development at the grassroots level. The assistance aims to protect those who are vulnerable due to various factors such as poverty and/or misfortunes that directly threaten their lives, livelihood, and dignity, as well as to promote self-reliance of local communities. Since 1991, the Government of Japan has provided over US$70 million for mainly local authorities and non-governmental organizations to implement 694 *KUSANONE* projects throughout Cambodia.

---

*Embassy of Japan in the Kingdom of Cambodia*
*Tel: 023-217-161*
*Email: eco.jpn@pp.mofa.go.jp*
*Website: http://www.kh.emb-japan.go.jp*

**ស្ថានទូតជប៉ុន**
**ប្រចាំព្រះរាជាណាចក្រកម្ពុជា**
**សេចក្តីប្រកាសព័ត៌មាន**

លេខ. 03PR-25/EoJ ថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៥

**ជប៉ុនផ្តល់ថវិកា ៤៤៦,៨០១ ដុល្លារអាមេរិក**
**សម្រាប់ការស្តារប្រព័ន្ធធារាសាស្ត្រ និងការសាងសង់ស្ពាន**

រដ្ឋាភិបាលជប៉ុន នឹងផ្តល់ថវិកាសរុបចំនួន ៤៤៦,៨០១ ដុល្លារអាមេរិក ដល់ស្ថាប័នទទួលជំនួយចំនួនបីក្រោមគ្រោងការណ៍ជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ (គូសាណូណិ)។ កិច្ចសន្យាផ្តល់ជំនួយ ត្រូវបានចុះហត្ថលេខានៅថ្ងៃនេះ ដោយ ឯកឧត្តម អ៊ូអិណុ អាត់ស៊ូស៊ី ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និង តំណាងស្ថាប័នទទួលជំនួយទាំងបី ដើម្បីអនុវត្តគម្រោងដូចតទៅ៖

**១. គម្រោងស្តារប្រព័ន្ធធារាសាស្ត្រត្រពាំងក្រែកក្នុងខេត្តតាកែវ (ថវិកាចំនួន ១៤០,៣៩៦ ដុល្លារអាមេរិក)**
ស្ថាប័នទទួលជំនួយ៖ មន្ទីរធនធានទឹក និងឧតុនិយមខេត្តតាកែវ

ជំនួយនេះ នឹងត្រូវបានប្រើប្រាស់ដើម្បីស្តារប្រព័ន្ធធារាសាស្ត្រមានស្រាប់ដែលមានមុខងារអាងស្តុកទឹកអន់ថយ។ តំបន់នេះងាយរងគ្រោះរាំងស្ងួតក្នុងរដូវប្រាំង ដោយសារប្រព័ន្ធធារាសាស្ត្រមិនអាចស្តុកទឹកបានគ្រប់គ្រាន់ក្នុងរដូវវស្សា។ មិនតែប៉ុណ្ណោះ ដោយសារសមត្ថភាពស្តុកទឹកមិនគ្រប់គ្រាន់ តំបន់នេះជារឿយៗរងផលប៉ះពាល់ដោយទឹកជំនន់។ ផ្លូវតភ្ជាប់ពីប្រព័ន្ធធារាសាស្ត្រនេះទៅតំបន់ដែលប្រជាជនរស់នៅ មានស្ថានភាពយ៉ាប់យឺន ដែលដាក់បន្ទុកយ៉ាងធ្ងន់ដល់កសិករ។ យើងរំពឹងថាគម្រោងនេះនឹងផ្តល់អត្ថប្រយោជន៍ដល់ប្រជាជនមូលដ្ឋានប្រមាណ ៣,០០០ នាក់ តាមរយៈការកែលម្អប្រព័ន្ធធារាសាស្ត្រ ដើម្បីធានាការផ្គត់ផ្គង់ទឹកសម្រាប់កសិកម្មប្រកបដោយស្ថិរភាពពេញមួយឆ្នាំ។ លើសពីនេះ យើងរំពឹងថាកម្រិតជីវភាពរស់នៅ និងប្រាក់ចំណូលរបស់ប្រជាជននឹងមានភាពប្រសើរឡើង ដោយសារមានការកើនឡើងនៃបរិមាណស្រូវដែលផលិតបាននៅក្នុងតំបន់នេះ។

**២. គម្រោងសាងសង់ស្ពានក្នុងឃុំឈូក ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ (ថវិកាចំនួន ១៥៤,៣៥៣ ដុល្លារអាមេរិក)**
ស្ថាប័នទទួលជំនួយ៖ មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តកំពង់ធំ

ជំនួយនេះ នឹងត្រូវបានប្រើប្រាស់ដើម្បីសាងសង់ស្ពានបេតុងថ្មីមួយ។ មានស្ពានមួយមិនទាន់សាងសង់រួចរាល់ ដែលត្រូវបានផ្អាកដោយសារខ្វះថវិកា។ បន្ទាប់ពីស្ពានរងការបាក់ស្រុតដោយទឹកជំនន់ក្នុងឆ្នាំ២០២៣ ប្រជាជនមូលដ្ឋានត្រូវឆ្លងកាត់ទន្លេដោយប្រើប្រាស់ទូកតូចមួយ។ ស្ពានថ្មីនេះនឹងផ្តល់ឱ្យប្រជាជនដែលរស់នៅក្នុងតំបន់នេះប្រមាណ ១១,០០០នាក់ ជាមួយនឹងការធ្វើដំណើរប្រកបដោយសុវត្ថិភាព។ លើសពីនេះទៅទៀត តាមរយៈការផ្តល់លទ្ធភាពក្នុងការដឹកជញ្ជូនកសិផល ប្រាក់ចំណូលរបស់ប្រជាជនមូលដ្ឋាននឹងមានការកើនឡើង។

<u>**៣. គម្រោងសាងសង់ស្ពានក្នុងឃុំខ្វាវ ស្រុកជីក្រែង ខេត្តសៀមរាប (ថវិកាចំនួន ១១២,០៥២ ដុល្លារអាមេរិក)**</u>

<u>*ស្ថាប័នទទួលជំនួយ៖ រដ្ឋបាលឃុំខ្វាវ*</u>

ជំនួយនេះនឹងត្រូវបានប្រើប្រាស់ដើម្បីសង់ស្ពានបេតុងថ្មីមួយ ជំនួសឱ្យស្ពានឈើពុកផុយបច្ចុប្បន្ន។ ខណៈដែលប្រជាជនមូលដ្ឋានជាច្រើនតែងតែឆ្លងកាត់ស្ពាននេះដើម្បីទៅសាលារៀន កន្លែងធ្វើការ និងមន្ទីរពេទ្យ ព្រមទាំងដឹកជញ្ជូនកសិផល ស្ពាននេះបានរងការខូចខាត និងគ្មានសុវត្ថិភាព ជាពិសេសសម្រាប់កុមារ និងមនុស្សចាស់។ បន្ថែមពីនេះ ឡាននិងរថយន្តសង្គ្រោះបន្ទាន់មិនត្រូវបានអនុញ្ញាតឱ្យឆ្លងកាត់ស្ពាននេះទេ ដោយសារស្ពាននេះប្រហែលមិនអាចទ្រាំទ្របាននូវទម្ងន់ និងអាចមានការបាក់ស្រុត។ យើងរំពឹងថាគម្រោងនេះនឹងផ្តល់អត្ថប្រយោជន៍ដល់ប្រជាជនប្រមាណ ១៥,០០០នាក់ តាមរយៈការធានាបាននូវផ្លូវធ្វើដំណើរប្រកបដោយសុវត្ថិភាពទៅសាលារៀន ផ្សារ និងមណ្ឌលសុខភាពដែលនៅជិតបំផុតពេញមួយឆ្នាំ។ ការសាងសង់ស្ពានថ្មីក៏នឹងជួយសម្រួលដល់ការដឹកជញ្ជូនកសិផលផងដែរ ដែលនឹងនាំមកនូវការកែលម្អកម្រិតជីវភាពរស់នៅរបស់ប្រជាជន និងការកើនឡើងនូវប្រាក់ចំណូលរបស់កសិករ។

ជំនួយឥតសំណងគូសាណូណិរបស់ជប៉ុន បានចាប់ផ្តើមនៅប្រទេសកម្ពុជានៅឆ្នាំ១៩៩១ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការអភិវឌ្ឍ និងស្តាបនាប្រទេសឡើងវិញ នៅតាមកម្រិតមូលដ្ឋាន។ ជំនួយឥតសំណងនេះ មានទិសដៅការពារជនងាយរងគ្រោះពីកត្តាមួយចំនួនដូចជា ភាពក្រីក្រ និង/ឬ ភាពអកុសលនានា ដែលអាចគំរាមកំហែងដោយផ្ទាល់ដល់អាយុជីវិត ជីវភាពរស់នៅ និងសេចក្តីថ្លៃថ្នូររបស់ពួកគេ ក៏ដូចជាជួយជំរុញនូវភាពម្ចាស់ការលើខ្លួនឯងរបស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ១៩៩១ រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង ៧០លាន ដុល្លារអាមេរិក ដល់អាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាល ដើម្បីអនុវត្តគម្រោងគូសាណូណិ ចំនួន ៦៩៤ គម្រោង នៅទូទាំងប្រទេសកម្ពុជា៕

---

*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*

*ទូរសព្ទ៖ ០២៣-២១៧-១៦១*

*អ៊ីម៉ែល៖ eco.jpn@pp.mofa.go.jp*

*គេហទំព័រ៖ http://www.kh.emb-japan.go.jp*

**សុន្ទរកថារបស់ ឯកឧត្តម អ៊ូអិណុ អាត់ស៊ូស៊ី**
**ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា**
**ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយឥតសំណង**
**សម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ**
**ថ្ងៃ៣០ ខែមករា ឆ្នាំ២០២៥**

សូមគោរព

- **ឯកឧត្តម ពេជ្រ វាសនា** អនុរដ្ឋលេខាធិការ នៃក្រសួងធនធានទឹក និងឧតុនិយម
- **លោក ប៊ុន ហួ** ប្រធានមន្ទីរធនធានទឹក និងឧតុនិយមខេត្តតាកែវ
- **លោក ជូ កុល្លា** ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តកំពង់ធំ
- **លោក ធិន ភី** រដ្ឋបាលឃុំខ្វាវ
- លោក លោកស្រី ភ្ញៀវកិត្តិយសទាំងអស់ជាទីមេត្រី។

អរុណសួស្តីអ្នកទាំងអស់គ្នា។ ខ្ញុំមានសេចក្តីសោមនស្សរីករាយដែលបានចូលរួមពិធីចុះហត្ថលេខាលើកិច្ចសន្យា ដែលនឹងត្រូវបានអនុវត្តក្រោម ជំនួយឥតសំណងគូសាណូណិសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ នាថ្ងៃនេះ។

ចាប់តាំងពីឆ្នាំ១៩៩១ រដ្ឋាភិបាលជប៉ុនបាននិងកំពុងអនុវត្តជំនួយឥតសំណងគូសាណូណិនៅកម្ពុជា ដើម្បីជួយដោយផ្ទាល់ដល់អាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាលនានា ក្នុងការអនុវត្តគម្រោងរបស់ពួកគាត់។ គូសាណូណិ មានន័យថា "ឫសស្មៅ" ក្នុងភាសាជប៉ុន ហើយនៅក្នុងរយៈពេលជាង៣០ឆ្នាំកន្លងមកនេះ ស្ថានទូតជប៉ុន បានអនុវត្តជិត ៧០០គម្រោង នៅទូទាំងប្រទេសកម្ពុជា តាមរយៈគ្រោងការណ៍ជំនួយឥតសំណងគូសាណូណិ។ យើងមានសេចក្តីសោមនស្សរីករាយដែលគម្រោងទាំងនេះបានចូលរួមចំណែកដោយផ្ទាល់ក្នុងការលើកកម្ពស់គុណភាពនៃជីវភាពរបស់ប្រជាជនកម្ពុជានៅកម្រិតមូលដ្ឋាន។

នាពេលនេះ ខ្ញុំសូមណែនាំគម្រោង ដែលយើងកំពុងចុះហត្ថលេខានាថ្ងៃនេះ។

សម្រាប់គម្រោងទី១ ដែលអនុវត្តដោយមន្ទីរធនធានទឹក និងឧតុនិយមខេត្តតាកែវ រដ្ឋាភិបាលជប៉ុនផ្តល់ថវិកាចំនួន ១៨០,៣៩៦ ដុល្លារអាមេរិក (មួយរយប៉ែតសិបពាន់បីរយកៅសិបប្រាំមួយដុល្លារអាមេរិក) សម្រាប់ការស្តារប្រព័ន្ធធារាសាស្ត្រក្នុងខេត្តតាកែវ។ ប្រព័ន្ធធារាសាស្ត្រទាំងនេះមិនត្រឹមតែចូលរួមចំណែកក្នុងការធានាការផ្គត់ផ្គង់ទឹកសម្រាប់កសិកម្មប្រកបដោយស្ថិរភាពប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងកែលម្អកម្រិតជីវភាពរស់នៅរបស់ប្រជាជន និងប្រាក់ចំណូលរបស់កសិករផងដែរ។

សម្រាប់គម្រោងទី២ ដែលអនុវត្តដោយមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តកំពង់ធំ រដ្ឋាភិបាលជប៉ុនផ្តល់ថវិកាចំនួន ១៥៤,៣៥៣ ដុល្លារអាមេរិក (មួយរយហាសិបបួនពាន់បីរយហាសិបបីដុល្លារអាមេរិ

ក) ដើម្បីសាងសង់ស្ពានបេតុងថ្មីមួយ នៅលើទន្លេមួយក្នុងខេត្តកំពង់ធំ។ ស្ពានថ្មីនេះនឹងផ្តល់ឱ្យប្រជាជនមូលដ្ឋានប្រមាណ ១១,០០០នាក់ នូវមធ្យោបាយធ្វើដំណើរដែលត្រឹមត្រូវ និងមានសុវត្ថិភាព។

សម្រាប់គម្រោងទី៣ ដែលអនុវត្តដោយរដ្ឋបាលឃុំខ្វាវ ក្នុងខេត្តសៀមរាប រដ្ឋាភិបាលជប៉ុនផ្តល់ថវិកាចំនួន ១១២,០៥២ ដុល្លារអាមេរិក (មួយរយដប់ពីរពាន់ហាសិបពីរដុល្លារអាមេរិក) ដើម្បីសាងសង់ស្ពានបេតុងថ្មីមួយ ជំនួសឱ្យស្ពានឈើពុកផុយបច្ចុប្បន្ន។ ស្ពាននេះនឹងជួយសម្រួលដល់ការដឹកជញ្ជូនកសិផល ហើយនឹងផ្តល់ឱ្យប្រជាជនមូលដ្ឋានប្រមាណ ១៥,០០០នាក់ នូវផ្លូវធ្វើដំណើរប្រកបដោយសុវត្ថិភាពទៅសាលារៀន ផ្សារ និងមណ្ឌលសុខភាពដែលនៅជិតបំផុត។

ខ្ញុំមានសេចក្តីសោមនស្សរីករាយ ដោយបានសង្កេតឃើញការអភិវឌ្ឍយ៉ាងឆាប់រហ័សរបស់ប្រទេសកម្ពុជានាពេលថ្មីៗនេះ។ ទោះជាយ៉ាងណា ខ្ញុំក៏ទទួលស្គាល់ថានៅតែមានបញ្ហាប្រឈមជាច្រើន ដែលជប៉ុនអាចជួយបាន ដើម្បីលើកកម្ពស់គុណភាពជីវិតរបស់ប្រជាជន។ ជប៉ុននឹងបន្តចូលរួមចំណែកក្នុងការដោះស្រាយបញ្ហាប្រឈមទាំងនោះ តាមរយៈគ្រោងការណ៍ជំនួយអភិវឌ្ឍន៍ផ្លូវការផ្សេងៗ រួមទាំង "គូសាណូណិ" ផងដែរ។

ជាចុងក្រោយ ខ្ញុំសូមជូនពរ ឯកឧត្តម លោក លោកស្រី ដែលមានវត្តមាននៅទីនេះ សូមមានសុខភាពល្អ សុភមង្គល និងសូមឱ្យមិត្តភាពជប៉ុន-កម្ពុជាកាន់តែរីកចម្រើន។

សូមអរគុណសម្រាប់ការយកចិត្តទុកដាក់ស្តាប់។